ជំហាន

នៃការដើរតាម

# ព្រះយេស៊ូវគ្រីស្ទ

សេចក្តីណែនាំ

សម្រាប់ការដើរតាម

និងការបង្កើតសិស្ស

**www.globalkfm.org**




កំណែ ១៤-សីហា-២៣ ១១:៤០



# តារាងមាតិកា៖ ឧបករណ៍

| | | | | |
|---|---|---|---|---|
|  | ស្រែទាំងបួន | គ្រាប់ពូជ<br>និងការប្រមូលផល | https://www.youtube.com/watch?v=i9c6KVAqObs | ទំព័រ៣ |
| ៤១១ | «៤១១»<br>វគ្គបណ្តុះបណ្តាលនៃការបង្កើតសិស្ស<br>ហេតុអ្វី? | ២កូរិនថូស ៥:១៧-២០<br>មនុស្សថ្មី និងទូត | https://www.youtube.com/watch?v=Q1c3sAZx0D4 | ទំព័រ៤ |
| | «៤១១»<br>វគ្គបណ្តុះបណ្តាលនៃការបង្កើតសិស្ស<br>នរណា? | ផែនទីផ្ទះ | https://www.youtube.com/watch?v=D5az2LAtDDw&t=13s | ទំព័រ៤ |
| | «៤១១»<br>វគ្គបណ្តុះបណ្តាលនៃការបង្កើតសិស្ស<br>អ្វី? | ទីបន្ទាល់ក្នុងរយៈពេល<br>១នាទីរបស់ខ្ញុំអំពីការដើរ<br>តាមព្រះជាម្ចាស់ | https://www.youtube.com/watch?v=hkprflNySS8 | ទំព័រ៥ |
| | ៤១១<br>វគ្គបណ្តុះបណ្តាលនៃការបង្កើតសិស្ស<br>អ្វី? | រង្វង់ទាំងបី | https://www.youtube.com/watch?v=5W8ynRMr59k | ទំព័រ៥ |
| | ៤១១<br>វគ្គបណ្តុះបណ្តាលនៃការបង្កើតសិស្ស<br>អ្វី? | ការបង្ហាញពីអំណាច<br>ព្រះជាម្ចាស់ | | ទំព័រ៥ |
| | ៤១១<br>វគ្គបណ្តុះបណ្តាលនៃការបង្កើតសិស្ស<br>ពេលណា? | ការកំណត់គោលដៅ | https://www.youtube.com/watch?v=QMrCCYrqQms | ទំព័រ៥ |
|  | រង្វង់នៃ<br>ក្រុមជំនុំ | | | ទំព័រ៦ |
| | ចាប់ពីការ<br>បង្កើតមក<br>ដល់ព្រះគ្រីស្ទ | | https://www.youtube.com/watch?v=g_c-p6_qLhU<br>(ទីបន្ទាល់ដ៏អស្ចារ្យ) | ទំព័រ៧ |
|  | កៅអីទាំងបី | | https://www.youtube.com/watch?v=lIatI5AAbJc | ទំព័រ៨ |
|  | ទ្វារ | | | ទំព័រ៩ |
| ១៣៩ | ការពហុគុណ | ២ធីម៉ូថេ ២:១-៦ | | ទំព័រ១០ |
| | ប្រោសអ្នកជំងឺ | របៀបដំណើរការ | | ទំព័រ១១ |

**កូនសៀវភៅណែនាំស្តីពី «១៥ជំហាននៃការដើរតាមព្រះគ្រីស្ទ» អាចទាញយកបាននៅ៖ www.globalkfm.org**

# ស្រែទាំងបួន

**ស្រែទី១ ៖ កសិករៀបចំដី ដើម្បីសាបព្រោះ ។**

មាតិកា ៖

- សេចក្តីអធិស្ឋាន
- ស្វែងរកផ្ទះនៃសេចក្តីសុខសាន្ត
- ផែនទីផ្ទះ
- សេចក្តីស្រឡាញ់

អត្ថបទព្រះគម្ពីរ ៖ **លូកា ១៩:១០** ដ្បិតកូនមនុស្សបានមក ដើម្បីស្វែងរក ហើយសង្គ្រោះមនុស្សបាត់បង់ ។

**ស្រែទី២ ៖ កសិករព្រោះគ្រាប់ពូជ ទៅលើដី ។**

មាតិកា:

- ចូលទៅកាន់ផ្ទះនៃសេចក្តីសុខសាន្ត
- ប្រកាសដំណឹងល្អ
- រាជរបស់ព្រះជាម្ចាស់មកដល់ហើយ
- ប្រោសអ្នកឈឺឲ្យបានជា
- ដេញវិញ្ញាណអាក្រក់
- ធ្វើបន្ទាល់
- សេចក្តីស្រឡាញ់

អត្ថបទព្រះគម្ពីរ ៖ **លូកា ១០:៥-៩**
ឯផ្ទះណាដែលអ្នករាល់គ្នាចូលទៅ មុនដំបូងត្រូវថា សូមឲ្យផ្ទះនេះបានសេចក្តីសុខសាន្ត បើនៅផ្ទះនោះមានមនុស្សណាចូលចិត្តនឹងសេចក្តីសុខសាន្ត នោះសេចក្តីសុខរបស់អ្នករាល់គ្នា នឹងនៅជាប់ក្នុងផ្ទះនោះ តែបើគ្មានទេ សេចក្តីសុខនោះនឹងត្រឡប់មកអ្នករាល់គ្នាវិញ ។ ចូរស្នាក់នៅផ្ទះនោះ ហើយបរិភោគរបស់អ្វីៗដែលគេឲ្យចុះ ព្រោះអ្នកដែលធ្វើការ គួរនឹងបានប្រាក់ឈ្នួល ។ កុំឲ្យផ្លាស់ពីផ្ទះមួយទៅផ្ទះមួយឡើយ ។ ឯភូមិណាដែលអ្នករាល់គ្នាចូលទៅ ហើយគេរាក់ទាក់ទទួល ចូរបរិភោគរបស់អ្វីៗដែលគេលើកមកឲ្យចុះ ទាំងមើលពួកអ្នកឈឺក្នុងភូមិនោះឲ្យជាផង ហើយប្រាប់គេថា «ព្រះរាជ្យរបស់ព្រះបានមកជិតអ្នករាល់គ្នាហើយ» ។

**៥.អ្នកដឹកនាំ**
គឺជាគំរូ ពួកគេគាំទ្រ ជម្រុញ មើល និងបញ្ជូនឲ្យចេញទៅ ។
អត្ថបទព្រះគម្ពីរ ៖
**១ពេត្រុស ៥:៣ ៖**
មិនមែនដោយប្រើអំណាចជិះជាន់អស់អ្នកដែលនៅជាមួយអ្នករាល់គ្នានោះទេ គឺធ្វើជាគំរូដល់ហ្វូងចៀមវិញ ។




**ស្រែទី៤ ៖**
**កសិករពីចម្រូតមកដាក់ក្នុងជម្រុកជាមួយគ្នា ហើយត្រៀមអ្វីៗសម្រាប់ការសាបព្រោះបន្ទាប់ ។ ផ្នែករបស់សហគមន៍ ។**

មាតិកា ៖

- បន្តកែច្នៃលក្ខណៈរបស់ផ្ទះ/វប្បធម៌សហគមន៍
- យល់ដឹងពីបណ្តាញ
- ១,៣,៩ គំនូសតាងពហុគុណ
- បើកស្វាគមន៍មនុស្ស និងផ្ទះថ្មី

អត្ថបទព្រះគម្ពីរ ៖ **កិច្ចការ ២:៣៦-៣៧**

ដូច្នេះ ចូរឲ្យវង្សអ៊ីស្រាអែលទាំងអស់ដឹងប្រាកដថា ព្រះបានតាំងព្រះយេស៊ូវនេះ ដែលអ្នករាល់គ្នាបានឆ្កាងឲ្យធ្វើជាព្រះអម្ចាស់ និងជាព្រះគ្រីស្ទ» ។កាលគេបានឮនោះគេមានការចាក់ចុចក្នុងចិត្ត ហើយសួរលោកពេត្រុស និងពួកសាវកឯទៀតថា ៖ «បងប្អូនអើយ តើយើងខ្ញុំត្រូវធ្វើដូចម្តេច?»

**ស្រែទី៣ ៖ កសិករមើលថែគ្រាប់ពូជ ដើម្បីឲ្យដំណាំលូតលាស់ បានល្អ ។**

មាតិកា ៖

- សិក្សាស្វែងយល់ព្រះគម្ពីរជាមួយគ្នា (១៩ជំហាន ជាពិសេសជំហានទី១-៨) ។
- ពិធីជ្រមុជទឹក អនុវត្តបង្កើតសិស្ស១ទល់នឹង១ ហើយនៅផ្ទះ
- ជំហានមូលដ្ឋានក្នុងការស្តាប់បង្គាប់នៃភាពជាសិស្ស និងក្នុងនាមជាទូតរបស់ព្រះគ្រីស្ទ

អត្ថបទព្រះគម្ពីរ ៖ **ម៉ាថាយ ២៨:១៩-២០**

ដូច្នេះ ចូរទៅបង្កើតឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើពិធីជ្រមុជទឹកឲ្យគេ ក្នុងព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ហើយបង្រៀនឲ្យគេកាន់តាមគ្រប់ទាំងសេចក្តីដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា ហើយមើល៍ ខ្ញុំក៏នៅជាមួយអ្នករាល់គ្នាជារៀងរាល់ថ្ងៃ រហូតដល់គ្រាចុងបំផុត» ។ អាម៉ែន

# ប្រការ «៤១១»

## វគ្គបណ្ដុះបណ្ដាលការបង្កើតសិស្ស

---



ក្រដាសមួយឈុត



បថក្រដាសចំពាក់កណ្ដាល

→ សូមអានកណ្ឌគម្ពីរ ម៉ាថាយ ២៨: ១៨-២០ «ចូរចេញទៅបង្កើតសិស្ស» ។

→ ប្រការ «៤១១» បង្រៀនអ្នកដើតាមព្រះយេស៊ូវ បង្កើតសិស្ស តាមរយៈការឆ្លើយ

ទៅនឹងសំណួរទាំង៤នេះ ក្នុងរយៈពេល១ម៉ោង (ឬតិចជាងនេះ) នោះលើក្រដាស់ ១សន្លឹក៖

| | | | |
|---|---|---|---|
| ១. ហេតុអ្វី បង្កើតសិស្ស? | ២. នរណា ត្រូវឈោងចាប់? | ៣. អ្វី ត្រូវនិយាយ? | ៤. ពេលណា ចាប់ផ្ដើម? |

---




→ សូមអាន **២កូរិនថូស ៥:១៧-២១**

→ **ឈើឆ្កាង៖** យើងឃើញតាមរយៈខគម្ពីរទាំងនេះថា បើសិនលោកអ្នកស្ថិតនៅក្នុងព្រះយេស៊ូវគ្រីស្ទ នោះកិច្ចការទាំងពីរនេះគឺពិតជាសម្រាប់លោកអ្នក៖

→ **ខ១៧** (បុគ្គល)-លោកអ្នកបានត្រឡប់ទៅថ្មីវិញ! ព្រះអង្គបានអត់ទោសរាល់អំពើបាបរបស់លោកអ្នក ។

→ **ខ២០** (សកលលោក)-ព្រះអង្គបានប្រទានអត្តសញ្ញាណថ្មីដល់យើង ធ្វើជាទូតរបស់ទ្រង់ ។

*លោកអ្នកមិនអាចបំបែកចរិតលក្ខណៈទាំងពីរនេះចេញពីគ្នាបានឡើយ ។ លោកអ្នកមិនអាចត្រឡប់ទៅជាថ្មីបានទេ ដោយមិនមែនជាទូតរបស់យេស៊ូវព្រះគ្រីស្ទផងទេនោះ ។ ហើយលោកអ្នកក៏មិនមែនជាទូតរបស់ព្រះយេស៊ូវគ្រីស្ទនោះទេ ដោយគ្មានការត្រឡប់ទៅជាថ្មីផងដែរ ។*




→

សូមទស្សនាវីឌីអូបង្រៀនអំពីមេរៀនទាំង៣នៅ ៖ **www.3circlesgospel.com**



# វដ្តនៃក្រុមជំនុំ

១. គូសរង្វង់ដាច់ៗមួយ ។ រង្វង់នេះតំណាងឲ្យវដ្តនៃការជួបជុំរបស់គ្រួសារក្រុមជំនុំ អ្នកជឿ ។ ជាញឹកញាប់ យើងហៅថា «វិហារ» ។



២. និមិត្តសញ្ញាផ្សេងៗ
តំណាងឲ្យលក្ខណៈជីវិតនៃការបង្កើតសិស្សដែលមានសុខភាពល្អ និងក្រុមជំនុំដែលមានសុខភាពល្អ ដូចដែលយើងឃើញនៅកណ្ឌគម្ពីរ កិច្ចការ ២:៣៦-៤៧ ។ ពួកគេបង្ហាញមកជា ១២ជំហាន ដើម្បីដើរតាមព្រះយេស៊ូវ ។






*សញ្ញាព្រួញតំណាងឲ្យសេចក្តីបង្គាប់របស់ព្រះយេស៊ូវឲ្យយើងប្រែចិត្ត ហើយជឿ ។ ភាគច្រើនគូសនៅខាងក្រៅរង្វង់ ។ នៅពេល មនុស្សទទួលពិសោធន៍នៅក្នុងសេចក្តីស្រឡាញ់ និងអំណាចនៃនគរព្រះជាម្ចាស់ វានឹងបង្កើតនូវទំនាក់ជាមួយព្រះយេស៊ូវ និងដំណើររបស់ពួកគេនៅក្នុងគ្រួសារក្រុមជំនុំ ។*

៣. គូសនិមិត្តសញ្ញានីមួយៗ ដែលលោកអ្នកបានអនុវត្តរួចរាល់ហើយ និងរស់នៅរួមជាមួយគ្នាជាគ្រួសារក្រុមជំនុំ ដូចនៅក្នុងរង្វង់ ។ សញ្ញាផ្សេងៗទៀត លោកអ្នកអាចដាក់នៅខាងក្រៅរង្វង់ ។



*នៅក្នុងឧទាហរណ៍ខាងលើ ក្រុមជំនុំបានអនុវត្ត និងបានទទួលយកលក្ខណៈសំខាន់ៗមួយចំនួននៃក្រុមជំនុំ ។ លក្ខណៈផ្សេងៗទៀតមិនទាន់កើតមាននៅក្នុងក្រុមជុំនុំនោះនៅឡើយទេ ។ លក្ខណៈទាំងអស់នេះនឹងអាចកើតមាន ហើយបញ្ជ្រាបបានបណ្តើរៗ...*

៤. គោលដៅនោះគឺ វិហារនីមួយៗដែលបានសង់ឡើង នឹងរីកចម្រើនឡើងក្លាយទៅជាគ្រួសារក្រុមជំនុំដែលមានសុខភាពល្អជាទី ដែលគ្រប់ទាំងលក្ខណៈសម្បត្តិរបស់ក្រុមជំនុំដំបូងបានរស់ជាមួយគ្នា ដូចនៅកណ្ឌគម្ពីរ កិច្ចការ ២:៣៦-៤៧ ។

ក្រុមជំនុំដែលមានសុខភាពល្អបែបនោះ ធ្វើបន្ទាល់អំពីព្រះយេស៊ូវទៅកាន់លោកីយ៍នៅក្នុងការជួបជុំជាលក្ខណៈក្រុមជំនុំ នៅផ្ទះ ព្រមទាំងមានការពហុគុណ មានការទទួលស្គាល់ពីសំណាក់មនុស្សដែលនៅជុំវិញពួកគេ ។



# ចាប់ពីការបង្កើតមកដល់ព្រះគ្រីស្ទ

**ចំណុចសំខាន់ទី១ បង្កើតមក ដើម្បីមានទំនាក់ទំនងជាមួយ និងមានសេរីភាព៖**

- ព្រះដ៏ខ្ពង់ខ្ពស់បំផុតបានបង្កើតសកលលោកមក ក្នុងរយៈពេល៦ថ្ងៃ
- មនុស្សត្រូវបានបង្កើតមកឲ្យចំនឹងរូបអង្គទ្រង់ ជាទីស្រឡាញ់របស់ព្រះវរបិតា
- ប្រទានឲ្យមានសេរីភាពក្នុងការជ្រើសរើស-មានអំណាចនឹងសម្រេចចិត្តប្រព្រឹត្តល្អបាន
- ការធ្លាក់ចុះរបស់ពួកទេវតា-អារក្សសាតាំង និងវិញ្ញាណអាក្រក់
- ការជ្រើសរើសមិនល្អ-ដាច់ចេញពីព្រះ
- ការព្យាយាមឲ្យបានគាប់ព្រះទ័យព្រះជាម្ចាស់ ដោយការប្រព្រឹត្តអ្វីដែលត្រឹមត្រូវដោយខ្លួនឯង-វាមិនអាចទៅរួចទេ
- ព្រះបន្ទូលសន្យាថា នឹងប្រទានព្រះអង្គសង្គ្រោះ ដើម្បីប្រោសលោះបាបរបស់មនុស្ស
- ព្រះអម្ចាស់ទតរំពៃថា មនុស្សនឹងត្រឡប់មកកាន់ព្រះវរបិតាវិញ
- ព្រះជាម្ចាស់បានប្រទានបញ្ញត្តិ១០ប្រការ និងអ្នកនាំសារជាច្រើន ដើម្បីបង្ហាញអំពីព្រះអង្គសង្គ្រោះ
- ការយកសត្វមកថ្វាយយញ្ញបូជា សម្រាប់ការអត់ទោសបាប
- មនុស្សមិនបានសុចរិត ដោយការប្រព្រឹត្តតាមក្រិត្យវិន័យឡើយ

## ចំណុចសំខាន់ទី២៖ ការផ្សះផ្សារជាមួយនឹងព្រះវរបិតាវិញ

---

- ព្រះទ្រង់ស្រឡាញ់មនុស្សលោកខ្លាំងដល់ម្លេះ បានជាទ្រង់ប្រទានព្រះរាជបុត្រាតែមួយរបស់ព្រះអង្គមកលោកីយ៍នេះ
- ព្រះយេស៊ូវបានយាងមក ហើយមានព្រះជន្មរស់នៅដោយសេចក្ដីស្រឡាញ់ និងពេញដោយការអស្ចារ្យផ្សេងៗ
- ឧទាហរណ៍ចំនួន៤អំពីការអស្ចារ្យ៖
    - មានអំណាចលើធម្មជាតិ៖ ធ្វើឲ្យរលកស្ងប់
    - បំពេញតម្រូវការរបស់មនុស្ស៖ ចម្អែតមនុស្ស ៥០០០នាក់
    - មានអំណាចលើវិញ្ញាណអាក្រក់ និងវិញ្ញាណផ្សេងៗ៖ ដេញវិញ្ញាណអាក្រក់
    - មានអំណាចលើសេចក្ដីស្លាប់៖ ប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ
- ព្រះយេស៊ូវមានព្រះជន្មរស់នៅក្នុងជីវិតដែលឥតខ្ចោះ ព្រះអង្គមិនដែលប្រព្រឹត្តបាបទាល់តែសោះ
- ព្រះអង្គជាកូនចៀមនៃព្រះ ជាយញ្ញបូជាដែលឥតខ្ចោះ
- ព្រះយេស៊ូវបានយាងមក ដើម្បីសម្រេចក្រិត្យវិន័យទាំង១០ប្រការ
- ព្រះបានធ្វើឲ្យព្រះអង្គត្រឡប់ជាតួបាបជំនួសយើង ដើម្បីឲ្យយើងបានត្រឡប់ជាសេចក្ដីសុចរិត ហើយត្រឡប់មកកាន់ទ្រង់វិញ
- មិនមែនដោយការប្រព្រឹត្តរបស់យើងទេ តែដោយសារអ្វីដែលព្រះអង្គបានធ្វើវិញ ហើយទទួលយកវា ។ នោះគឺជាការតាំងសញ្ញាថ្មី
- ព្រះយេស៊ូវ គឺជាផ្លូវតែមួយគត់ទៅឯទៅព្រះវរបិតា
- ព្រះអង្គមានព្រះជន្មរស់ពីសុគតឡើងវិញ ហើយមានព្រះជន្មគង់នៅសព្វថ្ងៃ

តើលោកអ្នកចង់ជឿ ប្រែចិត្ត ហើយត្រឡប់មកកាន់ព្រះជាម្ចាស់តាមរយៈព្រះបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទដែរឬទេ?

# កៅអីទាំងបីនៃអត្តសញ្ញាណ

ឥឡូវនេះ អ្វីដែលយើងធ្វើកំណត់ថា យើងជានរណា ។ ប៉ុន្តែ យើងជានរណា (ឬយើងគិតថា យើងជានរណានោះ) កំណត់នូវអ្វីដែលយើងធ្វើ ។

## តើលោកអ្នកស្ថិតនៅលើកៅអីមួយណា?


ការប្រព្រឹត្តិ


ការទទួលយក


អត្តសញ្ញាណ

មនុស្សព្យាយាម ដើម្បីបានការទទួលយកតាមរយៈការប្រព្រឹត្តិរបស់ពួកគេ ។ បើសិនជាអ្វីៗទាំងឡាយដំណើរការល្អ នោះការឲ្យតម្លៃលើខ្លួនរបស់ពួកគេកើនឡើង ហើយពួកគេមានអារម្មណ៍ថាខ្លាំងនៅក្នុងអត្តសញ្ញាណរបស់ខ្លួន ។ នៅពេលការប្រព្រឹត្តិបរាជ័យ នោះគ្រប់អ្វីៗទាំងអស់ក៏បរាជ័យផងដែរ ។

*ការជម្រុញទឹកចិត្តបឋម ៖ ការប្រកួតប្រជែង ។ របៀប ៖ ការងារ ។ បញ្ជីរបស់លោកអ្នក ៖ ការប្រព្រឹត្តរបស់លោកអ្នក ។ លទ្ធផល ៖ ការផ្តល់កិត្តិយស ។*


ការទទួលយក


អត្តសញ្ញាណ


ការប្រព្រឹត្តិ

គម្រោងការរបស់ព្រះជាម្ចាស់ គឺថាគ្រប់មនុស្សទាំងអស់អាចនឹងមានពិសោធន៍នៅក្នុងការទទួលយក និងសេចក្តីស្រឡាញ់ដ៏ល្អឥតខ្ចោះរបស់ទ្រង់ ព្រមទាំងដឹកនាំជីវិតពួកគេឲ្យបានចាក់ឫសយ៉ាងជ្រៅនៅក្នុងការទទួលយកនោះ ។ តាមរយៈការនេះ ជួយឲ្យពួកគេបានស្គាល់អត្តសញ្ញាណក្នុងនាមជាបុត្រធីតានៃព្រះជាម្ចាស់យ៉ាងច្បាស់ ។

ដោយការស្គាល់ពីអត្តសញ្ញាណ នោះការប្រព្រឹត្តនឹងស្តែងចេញមកជាមិនខាន ។

កណ្ឌគម្ពីរ យ៉ូហាន ១៥:៥ ខ្ញុំជាដើម អ្នករាល់គ្នាជាមែក អ្នកណាដែលនៅជាប់នឹងខ្ញុំ ហើយខ្ញុំនៅជាប់នឹងអ្នកនោះ ទើបអ្នកនោះបង្កើតផលជាច្រើន ដ្បិតបើដាច់ពីខ្ញុំ អ្នករាល់គ្នាមិនអាចធ្វើអ្វីបានឡើយ ។

យ៉ូហាន ១:១២, ម៉ាថាយ ៣:១៥-១៧, កូឡុស ២: ៩-១០, អេភេសូរ ៣: ១៤-២១, ១ពេត្រុស ២:៩

*ការជម្រុញទឹកចិត្តបឋម ៖ សេចក្តីស្រឡាញ់ពីព្រះវរបិតា និងរាល់កិច្ចការដែលព្រះយេស៊ូវបានសម្រេចសព្វគ្រប់ ។ របៀប ៖ ទុកចិត្ត ហើយពឹងអាងលើព្រះយេស៊ូវ ។ លោកអ្នកតំរៀបតាមលំដាប់ ៖ ព្រះបន្ទូលសន្យា និងជំនួយពីទ្រង់ ។ លទ្ធផល ៖ សិរីរុងរឿងដែលបានបើកសម្តែងឲ្យយើងឃើញនោះ មកពីទ្រង់ ហើយសម្រាប់ទ្រង់ ។*

# ឧបករណ៍ទ្វារ-ការឆ្លើយតបចំនួនបីចំពោះដំណឹងល្អ

«មើល៍! យើងឈរនៅមាត់ទ្វារទាំងគោះ បើអ្នកណាឮសំឡេងយើង ហើយបើកទ្វារឲ្យ នោះយើងនឹងចូលទៅក្នុងផ្ទះអ្នកនោះ យើងនឹងបរិភោគជាមួយអ្នកនោះ ហើយអ្នកនោះក៏បរិភោគជាមួយយើងដែរ» ។ វិវរណៈ ៣:២០

ព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ព្រះអង្គឈរទាំងគោះទ្វារដល់ដួងចិត្តរបស់មនុស្ស ។ ព្រះអង្គបញ្ជូនយើងទៅកាន់ពួកគេក្នុងនាមជាទូតទ្រង់ ហើយធ្វើការជាមួយពួកគេ ដើម្បីនាំពួកគេមកកាន់អង្គ (យ៉ូហាន ៦:៤៤) ។ នៅពេលដែលលោកអ្នកចាប់ផ្តើមចេញទៅកាន់វាលចម្រូត ហើយចែកចាយដំណឹងល្អនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ជាមួយនឹងមិត្តសម្លាញ់របស់លោកអ្នក សាច់ញាតិ និងអ្នកផ្សេងៗទៀត ។ លោកអ្នកនឹងជួបប្រទះនូវការឆ្លើយតបផ្សេងៗពីគ្នា ។ ការឆ្លើយតបទាំងបីនេះអាចរកឃើញនៅក្នុងព្រះគម្ពីរផងដែរ ។ កិច្ចការ ១៧:៣២-៣៤ *កាលគេបានឮអំពីមនុស្សស្លាប់រស់ឡើងវិញ មានខ្លះចំអកឲ្យ ហើយខ្លះទៀតពោលថា៖ «យើងនឹងស្តាប់អំពីរឿងនេះម្តងទៀត» ។ ដូច្នេះ លោកប៉ុលក៏ចេញពីចំណោមគេទៅ ។ ប៉ុន្តែ មានពួកគេខ្លះចូលរួមជាមួយលោក ហើយបានជឿ... (ទ្វារបើក...) ។*
*ឧបករណ៍ទ្វារបើក បង្ហាញពីការឆ្លើយតបទាំងនេះ ហើយផ្តល់នូវកម្លាំងដែលជួយលើរបៀបដែលយើងឆ្លើយតបទៅកាន់ពួកគេវិញ ។*

| ការឆ្លើយតបរបស់ពួកគេ | ការឆ្លើយតបរបស់ពួកយើង |
|---|---|
| **ទ្វារបិទ៖** ពួកគេនិយាយថា «ទេ» ។ ពួកគេធ្វើឲ្យអ្នកដឹងថា ពួកគេមិនចាប់អារម្មណ៍ ។ ប្រហែលជាពួកគេអាចនឹងនិយាយដោយល្អ ឬក៏ស្រែកគំហកដាក់អ្នក ។ | **បន្តស្វែងរក!** អធិស្ឋានសម្រាប់ពួកគេ ប៉ុន្តែបន្តទៅមុខទៀត ។ ព្រះជាម្ចាស់បានត្រៀមមនុស្សសម្រាប់ចម្រូត ។ បន្តដើរទៅទៀត រហូតដល់លោកអ្នករកឃើញពួកគេ ។* |
| **ទ្វារបើកតិចៗ៖** ពួកគេនិយាយថា «**ចាំមើលសិន**» ។ ពួកគេអាចនឹង និយាយថា «បាន ឬក៏មិន» ប៉ុន្តែគេចាប់អារម្មណ៍ ហើយត្រៀមចង់ដឹងបន្ថែមទៀត និងទទួលការអធិស្ឋាន ។ | **នាំពួកគេឲ្យស្គាល់ព្រះយេស៊ូវ** តាមរយៈព្រះបន្ទូល ។ លោកអ្នកអាចនឹងសួរពួកគេថា៖ «តើអ្នកចាប់អារម្មណ៍ចង់ហៅមិត្តភក្តិ និងក្រុមគ្រួសាររបស់អ្នកចូលរួមជាមួយយើងទេ យើងនឹងសិក្សាព្រះគម្ពីរ ដើម្បីស្វែងយល់ពីព្រះជាម្ចាស់ និងគម្រោងការរបស់ព្រះអង្គសម្រាប់ជីវិតយើងទាំងអស់គ្នា? |
| **ទ្វារបើក៖** ពួកគេនិយាយថា «បាទ/ចាស់» ។ នៅពេលលោកអ្នកកំពុងតែប្រាប់ពួកគេ ព្រះវិញ្ញាណដ៏វិសុទ្ធធ្វើការនៅក្នុងដួងចិត្តពួកគេ ហើយពួកគេចង់ប្រែចិត្ត ហើយជឿព្រះយេស៊ូវ ។ | **ចាប់ផ្តើមជាមួយពួកគេ ដោយអនុវត្តការបង្កើតសិស្ស ។** ប្រើជំហានទី៨នៃ «ការដើរតាមព្រះយេស៊ូវ» និងប្រើឧបករណ៍លេខ៤១១ ។ បើពួកគេត្រៀមខ្លួនរួចរាល់ហើយ លោកអ្នកអាចជ្រមុជទឹកឲ្យពួកគេតែម្តង ដូចនៅកណ្ឌគម្ពីរ កិច្ចការ ៨:២៦-៣៨ |



ព្រះយេស៊ូវ៖ តើអ្នករាល់គ្នាមិនថា «នៅបួនខែទៀតដល់រដូវចម្រូត» ទេឬ? តែខ្ញុំប្រាប់អ្នករាល់គ្នាថា ចូរមើលទៅវាលស្រែជុំវិញអ្នកចុះ ។ យ៉ូហាន ៤:៣៥ ស្រូវទុំល្អមច្រូតហើយ-នោះគឺជាការពិត!

បើសិនយើងបានជួបជាមួយនឹងមនុស្សដែលជាសិស្សរបស់ព្រះយេស៊ូវរួចហើយ លោកអ្នកយើងលើកទឹកចិត្តពួកគេឲ្យចូលរួមបម្រើជាមួយនឹងយើងដែរ នៅក្នុងចម្រូតដ៏សែនធំនេះ ។

* បើសិនជាមនុស្សស្ថិតនៅក្នុងបណ្តាញទំនាក់ទំនងរបស់លោកអ្នក-ជាសមាជិកគ្រួសារ មិត្តភក្តិ អ្នកជិតខាង ឬជាមិត្តរួមការងារ-ចាប់ផ្តើមអធិស្ឋានសម្រាប់ពួកគេ ជារៀងរាល់ថ្ងៃ ហើយរង់ចាំព្រះវិញ្ញាណដ៏វិសុទ្ធធ្វើការ ។ ព្រះជាម្ចាស់មានគម្រោងការសម្រាប់ជីវិតរបស់ពួកគេដោយមានហេតុផល ហើយការឆ្លើយតបរបស់លោកអ្នកនោះគឺគ្រាន់តែអត់ធ្មត់ ស្រឡាញ់ និងអធិស្ឋាន ។

# ឧបករណ៍លេខ ១៣៩

២ធីម៉ូថេ ២: ១–៦

១. ដូច្នេះ កូនអើយ ចូរមានកម្លាំងឡើង ដោយ សារព្រះគុណដែលនៅក្នុង ព្រះគ្រីស្ទយេស៊ូវ

២. ហើយអ្វីដែលអ្នកបានឮពីខ្ញុំ នៅមុខស្មរបន្ទាល់ជាច្រើន ត្រូវប្រគល់ឲ្យមនុស្សស្មោះត្រង់ ដែលមានសមត្ថភាពអាចបង្រៀនអ្នកផ្សេងទៀតបានដែរ ។

៣. ដូច្នេះ ចូរឲ្យអ្នកទ្រាំទ្រទុក្ខលំបាក ដូចជាទាហានយ៉ាងល្អរបស់ យេស៊ូវគ្រីស្ទចុះ

៤. ដូច្នេះ ចូររួមទុក្ខលំបាក ដូចទាហានដ៏ល្អរបស់ព្រះយេស៊ូវគ្រីស្ទចុះ ។

៥. ធម្មតាអ្នកដែលធ្វើទាហាន មិនជាប់ទាក់ទិននឹងកិច្ចការក្នុងជីវិតនេះទេ ព្រោះគាត់ខំឲ្យបានគាប់ចិត្តដល់អ្នកដែលកេណ្ឌខ្លួន ។

៦. ឯកីឡាករវិញ មិនបានទទួលពាក់ភួងជ័យឡើយ លុះត្រាតែគេប្រកួតតាមច្បាប់ ។



# ប្រោសអ្នកជំងឺ

ដោយផ្អែកលើ សេចក្តីពិត
នៃ ព្រះបន្ទូលព្រះជាម្ចាស់

អ្វី ៖ ប្រោសអ្នកជំងឺ! ម៉ាថាយ ១០:៨
នរណា ៖
អស់អ្នកណាដែលជឿ ម៉ាកុស ១៦:១៥-២០
ពេលណា ៖ ឥឡូវ! ២កូរិនថូស ៦:២

## ដោយសេចក្តីជំនឿ

រ៉ូម ១០:១៧; យ៉ាកុប ១:៦-៨ និង ២២; ម៉ាថាយ ៤:១-១១

**សួរសំណួរ ៖**
តើខ្ញុំអាចដាក់ដៃលើអ្នកបានទេ?
តើខ្ញុំអាចអធិស្ឋានឲ្យអ្នកបានទេ?

⊖ → **ប្រាប់គេអំពីព្រះយេស៊ូវ ៖**
ដំណឹងល្អ ទីបន្ទាល់របស់អ្នកជាមួយព្រះជាម្ចាស់...

↓ ⊕

ម៉ាកុស ១៨:៤១ **រង្វាស់នៃការ**

↓ ⊕

**ប្រោសឲ្យជា ៖**
ដោយនៅក្នុងសិទ្ធិអំណាច និងដោយទំនុកចិត្ត
ខ្លី ហើយសាមញ្ញ ដោយបើកភ្នែក!

↓ ⊕

ម៉ាកុស ១៦:១៨ **ដាក់ដៃលើ**

⊕ →

**អបអរសាទរ**



បានធូរខ្លះៗ
ឬមិនធូរទាល់តែសោះ
ម៉ាកុស៨:២៥

**ជាសះស្បើយ**
១០០%

**ការសាកល្បង ៖**
សួរសំណួរ ៖ អាចស្ទង់ដឹងពីការផ្លាស់ប្តូរ?
លែងឈឺចាប់?